# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១១៦ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## របបគោលនយោបាយចំពោះជនរងគ្រោះស្នាក់នៅក្នុងមជ្ឈមណ្ឌលរបស់រដ្ឋ

---

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០១ ចុះ ថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- បានឃើញអនុក្រឹត្យលេខ ៥៥ អនក្រ.បក ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ២០០៥ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី ០៦ ខែ តុលា ឆ្នាំ ២០០៦

## សម្រេច

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

មាត្រា ១.-

អនុក្រឹត្យនេះកំណត់អំពីរបបគោលនយោបាយចំពោះជនរងគ្រោះស្នាក់នៅក្នុងមជ្ឈមណ្ឌលរបស់រដ្ឋ ។

មាត្រា ២.-

មជ្ឈមណ្ឌលរបស់រដ្ឋ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ។

មាត្រា ៣.-

ជនរងគ្រោះទាំងឡាយ ដែលអនុក្រឹត្យនេះសំដៅដល់មានៈ ទារកកំព្រា កុមារកំព្រា កុមារ យុវកុមារ រងគ្រោះដោយសារការប្រើប្រាស់បំពានសារធាតុញៀនខុសច្បាប់ ដោយអំពើទាស់ខុសនឹងច្បាប់ ជនរងគ្រោះដោយសារការប្រើប្រាស់បំពានសារធាតុញៀនខុសច្បាប់ ជនរងគ្រោះដោយសារការជួញដូរមនុស្ស ជនពិការ ជនអនាថា និង ជនចាស់ជរាគ្មានទីពឹង ដែលស្នាក់នៅក្នុងមជ្ឈមណ្ឌលរបស់រដ្ឋ ហើយមានលក្ខណវិនិច្ឆ័យ ដូចមានចែងក្នុងមាត្រា ៤ ។

## ជំពូកទី ២

## លក្ខណវិនិច្ឆ័យជនរងគ្រោះ

មាត្រា ៤.-

លក្ខណវិនិច្ឆ័យជនរងគ្រោះ ស្នាក់នៅក្នុងមជ្ឈមណ្ឌលរបស់រដ្ឋ មានដូចតទៅ ÷

ក-ទារកកំព្រា កុមារកំព្រា ÷

១-ទារកកំព្រា កុមារកំព្រា ដែលមានអាយុ១៥ឆ្នាំចុះ ដែលឪពុកម្តាយស្លាប់ចោល ឬ បោះបង់ចោលដោយប្រការផ្សេងៗ និងគ្មានញាតិសន្តានយកទៅចិញ្ចឹម ។

២-ទារក កុមារ ដែលមានអាយុ១៥ឆ្នាំចុះ រស់នៅក្នុងគ្រួសារទីទ័លក្រ ឬ ពិការបាត់បង់សមត្ថភាពពលកម្ម ហើយគ្មានញាតិសន្តានយកទៅចិញ្ចឹម ។

ខ-កុមារ យុវកុមារ ដែលមានអាយុចាប់ពី ៧ឆ្នាំ ដល់ក្រោម ១៨ឆ្នាំ រងគ្រោះដោយសារការប្រើប្រាស់បំពានសារធាតុញៀនខុសច្បាប់ ដោយអំពើទាស់ខុសនឹងច្បាប់ ត្រូវបានឪពុកម្តាយ អាណាព្យាបាល អាជ្ញាធរមានសមត្ថកិច្ច មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ខេត្ត-ក្រុង បញ្ជូនមកមជ្ឈមណ្ឌលរដ្ឋ ។

គ-ជនដែលរងគ្រោះ ដោយសារការប្រើប្រាស់បំពានសារធាតុញៀនខុសច្បាប់ ហើយត្រូវបានគ្រួសារ អាជ្ញាធរមានសមត្ថកិច្ច មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ខេត្ត-ក្រុង បញ្ជូនមកមជ្ឈមណ្ឌលរដ្ឋ ។

ឃ-ជនដែលរងគ្រោះ ដោយសារការជួញដូរមនុស្ស ហើយត្រូវបានអាជ្ញាធរមានសមត្ថកិច្ច មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ខេត្ត-ក្រុង បញ្ជូនមកមជ្ឈមណ្ឌលរដ្ឋ ។

ង-ជនពិការ ជនអនាថា និង ជនចាស់ជរាគ្មានទីពឹង គ្មានជំរក គ្មានសាច់សារលោហិតជួយចិញ្ចឹមថែទាំ គ្មានលទ្ធភាពប្រកបមុខរបរដោយផ្ទាល់ខ្លួន អាចទទួលការស្តារលទ្ធភាពពលកម្ម ឬ ការបណ្តុះបណ្តាលវិជ្ជាជីវៈបាន ។

## ជំពូកទី ៣

## របបគោលនយោបាយចំពោះជនរងគ្រោះ

### មាត្រា ៥.-

ទារកកំព្រា កុមារកំព្រា កុមារ យុវកុមារ រងគ្រោះដោយសារការប្រើប្រាស់បំពានស្ថារធាតុញៀនខុសច្បាប់ ដោយអំពើទាស់ខុសនឹងច្បាប់ ជនរងគ្រោះដោយសារការប្រើប្រាស់បំពានសារធាតុញៀនខុសច្បាប់ ជនរងគ្រោះដោយសារការជួញដូរមនុស្ស ជនពិការ ជនអនាថា និង ជនចាស់ជរាគ្មានទីពឹង ត្រូវបានទទួលការចិញ្ចឹមបីបាច់ថែទាំ ស្តារលទ្ធភាពពលកម្ម ផ្គត់ផ្គង់ជីវភាព អប់រំ បណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ និងត្រូវបានធ្វើសមាហរណកម្មទៅក្នុងសហគមន៍ ។

### មាត្រា ៦.-

ជនរងគ្រោះដូចមានចែងក្នុងមាត្រា ៣ ខាងលើ ត្រូវបានទទួលរបបគោលនយោបាយថែទាំដូចខាងក្រោម ៖

| ល.រ | ប្រភេទមុខសញ្ញា និង កម្រិតអាយុ | ចំនួន មុខសញ្ញា | ចំនួន មេដោះ ឬអ្នកថែទាំ | ប្រភេទបុគ្គលិក |
|---|---|---|---|---|
| ១ | ទារកកំព្រា កុមារកំព្រា | | | |
| ១.១ | អាយុ១ឆ្នាំចុះ | ៣ នាក់ | ១ នាក់ | មន្ត្រីរាជការឬជាប់កិច្ចសន្យា |
| ១.២ | អាយុលើសពី ១ឆ្នាំដល់ ៣ឆ្នាំ | ៥ នាក់ | ១ នាក់ | មន្ត្រីរាជការឬជាប់កិច្ចសន្យា |
| ១.៣ | អាយុលើសពី ៣ឆ្នាំ | ១០-១៥នាក់ | ១ នាក់ | មន្ត្រីរាជការឬជាប់កិច្ចសន្យា |

| | | | | |
|---|---|---|---|---|
| ១.៤ | ទារកកំព្រា កុមារកំព្រាពិការធ្ងន់ធ្ងរ ឬកើតជំងឺអេដស៍ (AIDS) | ២ នាក់ | ១ នាក់ | មន្ត្រីរាជការឬជាប់កិច្ចសន្យា |
| ២ | **កុមារ យុវកុមារ រងគ្រោះដោយសារការប្រើប្រាស់បំពានសារធាតុញៀនខុសច្បាប់ ដោយអំពើទាស់ខុសនឹងច្បាប់** | | | |
| ២.១ | អាយុពី ៧ឆ្នាំដល់ក្រោម ១៨ឆ្នាំ | ១០ នាក់ | ១នាក់ | មន្ត្រីរាជការឬជាប់កិច្ចសន្យា |
| ៣ | **ជនរងគ្រោះដោយសារការប្រើប្រាស់បំពានសារធាតុញៀនខុសច្បាប់** | | | |
| ៣.១ | អាយុពី ១៨ឆ្នាំឡើង | ១០ នាក់ | ១ នាក់ | មន្ត្រីរាជការឬជាប់កិច្ចសន្យា |
| ៤ | **ជនរងគ្រោះដោយសារការជួញដូរមនុស្ស** | | | |
| ៤.១ | អាយុក្រោម ១៨ឆ្នាំចុះ | ១០ នាក់ | ១ នាក់ | មន្ត្រីរាជការឬជាប់កិច្ចសន្យា |
| ៤.២ | អាយុពី ១៨ឆ្នាំឡើង | ១៥ នាក់ | ១ នាក់ | មន្ត្រីរាជការឬជាប់កិច្ចសន្យា |
| ៥ | **ជនពិការ ជនអនាថា និង ជនចាស់ជរាគ្មានទីពឹង** | | | |
| ៥.១ | ជនពិការបាត់បង់សមត្ថភាពពលកម្មគ្មានទីពឹង | ៥ នាក់ | ១ នាក់ | មន្ត្រីរាជការឬជាប់កិច្ចសន្យា |
| ៥.២ | ជនអនាថា និង ជនចាស់ជរាគ្មានទីពឹង | ១៥ នាក់ | ១ នាក់ | មន្ត្រីរាជការឬជាប់កិច្ចសន្យា |
| ៥.៣ | ជនពិការទទួលការស្តារលទ្ធភាពពលកម្ម និង បណ្តុះបណ្តាលមុខជំនាញវិជ្ជាជីវៈ | ១៥ នាក់ | ១ នាក់ | មន្ត្រីរាជការឬជាប់កិច្ចសន្យា |

មាត្រា ៧.-

ប្រាក់ឧបត្ថម្ភចំពោះទារកកំព្រា កុមារកំព្រា កុមារ យុវកុមារ រងគ្រោះដោយសារការប្រើប្រាស់បំពានសារធាតុញៀនខុសច្បាប់ ដោយអំពើទាស់ខុសនឹងច្បាប់ ជនរងគ្រោះដោយសារការប្រើប្រាស់បំពានសារធាតុញៀនខុសច្បាប់ ជនរងគ្រោះដោយសារការជួញដូរមនុស្ស ជនពិការ ជនអនាថា និង ជនចាស់ជរាគ្មានទីពឹង មានដូចខាងក្រោម ៖

| ល.រ | ប្រភេទមុខសញ្ញា និងកម្រិតអាយុ | ចំនួនឯកតា ក្នុង ១នាក់ | ប្រាក់ ឧបត្ថម្ភ (៛) | ប្រភេទមុខចំណាយ | កំណត់សំគាល់ |
|---|---|---|---|---|---|
| ១ | *ទារកកំព្រា កុមារកំព្រា ទារក កុមារពិការធ្ងន់ធ្ងរ មានជំងឺរ៉ាំរ៉ៃ ផ្ទុកមេរោគ ឬមានជំងឺអេដស៍ (HIV/ AIDS)* | | | | |
| ១.១ | ទារកអាយុ២ឆ្នាំចុះ | ១ខែ | ៦០.០០០៛ | ទឹកដោះគោ | |
| | | ១ដង ក្នុង១ឆ្នាំ | ១២០.០០០៛ | សម្លៀកបំពាក់ សម្ភារៈដំណេក អនាម័យ និងព្យាបាល | ទទួលពេលដើមឆ្នាំ |
| ១.២ | កុមារអាយុលើសពី ២ឆ្នាំ | ១ខែ | ៤៥.០០០៛ | ម្ហូបអាហារ | |
| | | ១ដង ក្នុង១ឆ្នាំ | ១២០.០០០៛ | សម្លៀកបំពាក់ សម្ភារៈសិក្សា កីឡា សម្ភារៈដំណេក ផ្ទះបាយ អនាម័យ និងព្យាបាល | ទទួលពេលដើមឆ្នាំ |
| ១.៣ | ទារក កុមារពិការធ្ងន់ធ្ងរមានជំងឺរ៉ាំរ៉ៃ ផ្ទុកមេរោគអេដស៍ ឬមានជំងឺអេដស៍ (HIV/AIDS) | ១ខែ | ២០.០០០៛ | បំប៉នសុខភាព | |
| ១.៤ | ទារក កុមារអាយុ៥ឆ្នាំចុះ ទទួលមរណភាព | ១ដងគត់ | ២៧០.០០០៛ | រៀបចំពិធីបុណ្យសព | ស្មើប្រាក់ម្ហូបអាហារ ៦ខែ |
| ១.៥ | កុមារអាយុលើសពី ៥ឆ្នាំឡើង ទទួលមរណភាព | ១ដងគត់ | ៥៤០.០០០៛ | រៀបចំពិធីបុណ្យសព | ស្មើប្រាក់ម្ហូបអាហារ ១២ខែ |
| ១.៦ | អាយុពី ១៨ឆ្នាំ ឡើង | ១ដងគត់ | ១.០៨០.០០០៛ | សមាហរណកម្ម | ស្មើប្រាក់ម្ហូបអាហារ ២៤ខែ |
| ២ | *កុមារ យុវកុមារ រងគ្រោះដោយសារការប្រើប្រាស់បំពានសារធាតុញៀនខុសច្បាប់ ដោយអំពើទាស់ខុសនឹងច្បាប់ និង ជនរងគ្រោះដោយសារការប្រើប្រាស់បំពានសារធាតុញៀនខុសច្បាប់* | | | | |

| | | | | | |
|---|---|---|---|---|---|
| ២.១ | កុមារ យុវកុមារអាយុពី ៧ឆ្នាំ ដល់ក្រោម ១៨ឆ្នាំ និង ជនរងគ្រោះដោយសារការប្រើប្រាស់ បំពានសារធាតុញៀនខុសច្បាប់ | ១ ខែ | ៤៥.០០០៛ | ម្ហូបអាហារ | |
| | | ១ឆ្នាំ | ១២០.០០០៛ | សម្លៀកបំពាក់ សម្ភារៈសិក្សា កីឡា សម្ភារៈដំណេក ផ្ទះបាយ អនាម័យ និង ព្យាបាល | ទទួលពេលដើមឆ្នាំ |
| | | ១វគ្គ | ៣៩០.០០០៛ | បណ្តុះបណ្តាលមុខជំនាញវិជ្ជាជីវៈ | រយៈពេលខ្លី ៣ខែ |
| | | ១ដងគត់ | ២២៥.០០០៛ | សមាហរណកម្ម | ស្មើប្រាក់ម្ហូបអាហារ ៥ខែ |
| ៣ | *ជនរងគ្រោះដោយសារការជួញដូរមនុស្ស* | | | | |
| ៣.១ | ជនរងគ្រោះដោយសារការជួញដូរមនុស្ស | ១ខែ | ៤៥.០០០៛ | ម្ហូបអាហារ | |
| | | ១ឆ្នាំ | ១២០.០០០៛ | សម្លៀកបំពាក់ សម្ភារៈសិក្សា កីឡា សម្ភារៈដំណេក ផ្ទះបាយ អនាម័យ និង ព្យាបាល | ទទួលពេលដើមឆ្នាំ |
| | | ១វគ្គ | ៣៩០.០០០៛ | បណ្តុះបណ្តាលមុខជំនាញវិជ្ជាជីវៈ | រយៈពេលខ្លី ៣ខែ |
| | | ១ដងគត់ | ៨១០.០០០៛ | សមាហរណកម្ម | ស្មើប្រាក់ម្ហូបអាហារ ១៨ខែ |
| ៤ | *ជនពិការ ជនអនាថា និង ជនចាស់ជរាគ្មានទីពឹង* | | | | |
| ៤.១ | ជនពិការ ជនអនាថា និង ជនចាស់ជរាគ្មានទីពឹង | ១ខែ | ៤៥.០០០៛ | ម្ហូបអាហារ | |
| | | ១ឆ្នាំ | ១២០.០០០៛ | សម្លៀកបំពាក់ សម្ភារៈសិក្សា កីឡា សម្ភារៈដំណេក ផ្ទះបាយ អនាម័យ និង ព្យាបាល | ទទួលពេលដើមឆ្នាំ |

| | | | | | |
|---|---|---|---|---|---|
| ៤.២ | ជនពិការបាត់បង់សមត្ថភាពពលកម្មធ្ងន់ធ្ងរ ជនអនាថា ជនចាស់ជរាគ្មានទីពឹង និង ជនពិការមាន ជំងឺអេដស៍ (AIDS) | ១ខែ | ២០,០០០៛ | ចំបន់សុខភាព | |
| ៤.៣ | ជនពិការអនាថាដែលមាន ជំងឺអេដស៍ (AIDS) | ១វគ្គ | ៣៩០,០០០៛ | បណ្តុះបណ្តាលមុខជំនាញវិជ្ជាជីវៈ | រយៈពេលខ្លី ៣ខែ |
| ៤.៤ | ជនពិការ ជនអនាថា និងជនចាស់ជរាគ្មានទីពឹងទទួលមរណភាព | ១ដងគត់ | ៥៤០,០០០៛ | រៀបចំពិធីបុណ្យសព | ស្មើប្រាក់ម្ហូបអាហារ ១២ខែ |
| ៤.៥ | ជនពិការ ជនអនាថា និង ជនចាស់ជរាគ្មានទីពឹង | ១ដងគត់ | ៨១០,០០០៛ | សមាហរណកម្ម | ស្មើប្រាក់ម្ហូបអាហារ ១៨ខែ |

មាត្រា ៨.-

នីតិវិធី និងសំណុំលិខិតនៃការបញ្ចូល បញ្ចេញ និងធ្វើសមាហរណកម្មជនរងគ្រោះ ដូចមានចែងក្នុងមាត្រា ៣ នៃអនុក្រឹត្យនេះ ត្រូវកំណត់ដោយប្រកាសរដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ។

## ជំពូកទី ៤
## អវសានប្បញ្ញត្តិ

មាត្រា ៩.-

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ១០.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀង១ខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី២៦ ខែតុលា ឆ្នាំ ២០០៦

ហ៊ុន សែន

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ១០
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ